00911901

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 05 / 2013
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E2/20

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អនុស្សរណៈ - អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

**ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣**

**ជូនចំពោះ៖** **ភាគីនៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក /លោកស្រីចៅក្រមទាំងអស់ និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **ការបន្តបណ្តឹងរដ្ឋប្បវេណីដោយសិទ្ធិវន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាពនៅក្នុងសំណុំរឿង ០០២**

១. កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហុង គីមសួន និង Silke STUDZINSKY បានដាក់សំណើមួយ (ឯកសារ E2/8) ដោយបានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា កូនក្តីរបស់ពួកគាត់ដែលមានរហស្សនាម D22/1723 បានទទួលមរណភាពហើយ។ នៅក្នុងសំណើនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានជូនដំណឹងមកអង្គជំនុំជម្រះថា កូនប្រុសរបស់កូនក្តីរបស់ពួកគាត់នឹងបន្តបណ្តឹងរដ្ឋប្បវេណីនេះ។ ភ្ជាប់ទៅនឹងសំណើនោះគឺមានលិខិតបញ្ជាក់មរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាមខាងលើ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ សេចក្តីបញ្ជាក់របស់ប្រធានឃុំដែលពាក់ព័ន្ធ សេចក្តីបញ្ជាក់របស់សិទ្ធិវន្ត ព្រមទាំងឯកសារអំពីអត្តសញ្ញាណរបស់សិទ្ធិវន្តរូបនេះ។

២. កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សំ

សុគង់ និង Lyma NGUYEN បានដាក់សំណើមួយ (ឯកសារ E2/9) ដោយបានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា កូនក្តីរបស់ពួកគាត់ដែលជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D230/2/25 បានទទួលមរណភាពហើយ។ នៅក្នុងសំណើនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងមកអង្គជំនុំជម្រះថា ភរិយារបស់កូនក្តីរបស់ពួកគាត់បានបង្ហាញអំពីបំណងប្រាថ្នាចង់ក្លាយខ្លួនជាអ្នកបន្តបណ្តឹងរដ្ឋប្បវេណីរបស់ស្វាមីគាត់។ ភ្ជាប់ទៅនឹងសំណើនេះ គឺមានលិខិតបញ្ជាក់មរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ សេចក្តីបញ្ជាក់របស់សិទ្ធិវ័ន្ត ព្រមទាំងឯកសារអំពីអត្តសញ្ញាណ និងឯកសារអំពីលំនៅដ្ឋានរបស់សិទ្ធិវ័ន្តរូបនេះ។

៣. កាលពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជេត វណ្ណលី ក៏បានដាក់សំណើចំនួន ០២ ដោយបានជូនដំណឹងមកអង្គជំនុំជម្រះថា កូនក្តីរបស់គាត់ដែលជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/721 និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/728 បានទទួលមរណភាពហើយ។ នៅក្នុងសំណើទាំងនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងមកអង្គជំនុំជម្រះថា កូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/721 និងភរិយារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/728 បានបង្ហាញអំពីបំណងប្រាថ្នាចង់ក្លាយខ្លួនជាអ្នកបន្តបណ្តឹងរដ្ឋប្បវេណីរបស់កូនក្តីរបស់ពួកគាត់។ ភ្ជាប់ទៅនឹងសំណើទាំងនេះគឺមានលិខិតបញ្ជាក់មរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/721 ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ និង ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/728 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១០ ព្រមទាំងសេចក្តីបញ្ជាក់ និងអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់សិទ្ធិវ័ន្ត។

៤. កាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គីម ម៉េងឃី បានដាក់សំណើមួយដោយបានជូនដំណឹងមកអង្គជំនុំជម្រះថា កូនក្តីរបស់គាត់ដែលមានរហស្សនាម D22/3690 បានទទួលមរណភាពហើយ។ នៅក្នុងសំណើនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងមកអង្គជំនុំជម្រះថា កូនស្រីរបស់កូនក្តីគាត់មានបំណងចង់ក្លាយខ្លួនជាអ្នកបន្តបណ្តឹងរដ្ឋប្បវេណីពីម្តាយដែលបានទទួលមរណភាព។ ភ្ជាប់ទៅនឹងសំណើនេះគឺមានលិខិតបញ្ជាក់មរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមាន

E2/20

រហស្សនាមដូចខាងលើ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៣ សំណើរបស់សិទ្ធិវ័ន្ត និងឯកសារអត្តសញ្ញាណរបស់សិទ្ធិវ័ន្តរូបនេះ។

៥. បន្ទាប់ពីបានទទួលសំណើសុំ និងឯកសារភ្ជាប់ទាំងនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៥ រូបនេះត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ហើយមានការបញ្ជាក់ថា កូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/1723 ភរិយារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D230/2/25 កូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/721 ភរិយារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/728 និងកូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/3690 មានគុណវុឌ្ឍិធ្វើជាសិទ្ធិវ័ន្តបាន។

៦. អនុលោមតាមសំអាងហេតុដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព E2/5/3 នៅក្នុងសំណុំរឿង ០០១ (ឯកសារ E2/5/3 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩) អង្គជំនុំជម្រះសាលាដំបូងសម្រេចថា កូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/1723 ភរិយារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D230/2/25 កូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/721 ភរិយារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/728 និងកូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម D22/3690 អាចបន្តបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ក្នុងនាមជាសិទ្ធិវ័ន្តនៅក្នុងសំណុំរឿង ០០២។